# ខ្លឹមសារ
# និមិត្តសញ្ញារបស់ខេត្តតាកែវ

( Vishnu )



*រូបព្រះវិស្ណុដៃ៨ ( Vishnu )*
*ដាក់តាំងនៅសារមន្ទីរជាតិភ្នំពេញ*
*( រូបពិត )*




*រូបព្រះវិស្ណុដៃ៨ ( Vishnu ) ទីតាំងនៅខេត្តតាកែវ*
*( រូបចម្លង )*

## I, ព្រះវិស្ណុ ឬព្រះនារាយណ៍

ព្រះវិស្ណុ ឬព្រះនារាយណ៍ ជាអាទិទេពមួយអង្គក្នុងចំណោមអាទិទេពធំៗទាំងបី ក្នុងព្រាហ្មណ៍សាសនា។ ព្រះវិស្ណុមានតួនាទី ជាអាទិទេពស្រោចស្រង់លោក បង្កើតលោក មើលថែរក្សាលោក ឲ្យបានសេចក្តីសុខសាន្តមានឯករាជ្យយ៉ាងបរិបូរណ៍ និងរៀបចំច្បាប់ទម្លាប់ឱ្យបានត្រឹមត្រូវ។

## II, គេតនភ័ណ្ឌ

**១. កាន់ភ្លើងៈ** តំណាងឱ្យពន្លឺដែលអាចជួយបំភ្លឺកពផែនដី ដល់ជីវិតមនុស្ស សត្វ និងរុក្ខជាតិ។

២. ព្រនង់: គឺតំណាងឲ្យវិស័យការពារជាតិ និងមានកងកម្លាំងប្រដាប់អាវុធដ៏រឹងមាំរបស់ជាតិ សម្រាប់ការពារជាតិមាតុភូមិ ការពារភាពសុខសានរបស់ប្រជាពលរដ្ឋ ។

៣. ស្បែកប្រើស: (ម្រឹគា) គឺតំណាងឲ្យតាបសដែលរស់នៅក្នុងព្រៃតាំងសមាធិ និងប្រកាន់សច្ចធម៌ តំណាងឲ្យការគោរពប្រណិប័តន៍សាសនា ។

៤. គម្ពី: គឺតំណាងឲ្យគម្ពីរវេទ(ច្បាប់ក្បួនខ្នាត សម្រាប់គ្រប់គ្រង និង បង្រៀនដល់មនុស្ស

៥. ខ្យងស័ង្ខ: តំណាងឲ្យទំនៀមទំលាប់ដ៏ល្អផូរផង់ របស់ខ្មែរ ទឹកភាពត្រជាក់ត្រជុំនៃការរស់នៅរបស់ជីវិត សត្វលោក ជីវិតចាប់ផ្ដើកើតចេញពីទឹក ដែលជាលំនៅឋានរបស់ខ្យងស័ង្ខ។

៦. ខ្សែពួ: តំណាងឲ្យភាពសាមគ្គី ជាការសាមគ្គីផ្ទៃក្នុងយ៉ាងមាំ គឺការសាមគ្គីផ្ទៃក្នុងជាតិខ្មែរ ដែលមិនអាចឲ្យសត្រូវបំបែកបំបាក់បាន។

៧. កាំរន្ទះ ឬវជ្រ: តំណាងឲ្យឥទ្ធិពលនៃ អំណាចដ៏អស្ចារ្យ អាចបំភ្លឺភពផែនដីបានបំផ្លាញសភាវៈក្រក់ចោលនិងការពារនូវអ្វីដែលជាសភាវៈល្អ។

៨. ចូទឹក: តំណាងឲ្យទឹកអម្រឹតត្រជាក់ត្រជុំ អាចធ្វើឲ្យមនុស្ស សត្វរស់ឡើងវិញ ជាឱសថព្យាបាល ដ៏សក្ដិសិទ្ធនាំឲ្យចាកផុតទុក្ខទាំងពួង។

សរុបមកការសាងសង់ព្រះវិស្ណុ ឬព្រះនារាយណ៍ ជានិមិត្តរូបនៃខេត្ត គឺការដឹងគុណនៃការគោរពទៅលើព្រះវិស្ណុនាសម័យ ហ្វូណន ឬសម័យនគរភ្នំ(ព្រះវិស្ណុមានប្រភពពីស្រុកអង្គរបុរី)ដែលជាទឹកដីកំណើតនៃការកកើតអារ្យធម៌ និងវប្បធម៌ប្រពៃណីជាតិខ្មែរ តរៀងមកនៅសម័យមុនអង្គរ។ ហើយព្រះវិស្ណុក៏ជាទេពមួយអង្គតំណាងឲ្យសភាវៈល្អ ក្នុងការថែរក្សាលោក និងបានបង្ហាញនូវមហិទ្ធិឫទ្ធិដ៏អស្ចារ្យចំពោះមនុស្សលោកនាំមកនូវសេចក្ដីសុខសាន្ត និងសុភមង្គលក្នុងជីវិតប្រចាំថ្ងៃ ហេតុនេះហើយបានជាខេត្តតាកែវតម្រូវយកព្រះវិស្ណុដៃប្រាំបីនេះជានិមិត្តរូបរបស់ខេត្តតាកែវ។

រៀបរៀងដោយ លោក ឈន ប៊ុនហាក់ អនុប្រធានការិយាល័យបេតិកភណ្ឌនៃ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ
អាសយដ្ឋានៈ ផ្លូវក្រុងលេខ៤ ភូមិ៣ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវទូរស័ព្ទ/ទូរសារ 032 931 629, E-mail : takoe.culture@gmail.com / facebookpage